# មេរៀនទី ១៧៖ ព្រះយេស៊ូវត្រូវបានឆ្កាង

លូកា ១៩៖២៨-៤០ & ២៣៖១-៤៩

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/VVjyFEw8isk

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/UBe5OdA6NDM

**គោលបំណង៖** ព្រះយេស៊ូវសុគតដើម្បីលោះបាបយើង

**ខគម្ពីរចងចាំ៖** រ៉ូម ៦៖២៣ «ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា»។

**ចំរៀង** ( *យូធូបលីង* )៖

១.ហូសាណា https://youtu.be/QWQ47zCVaCw

២.មានទន្លេជីវិត https://youtu.be/AP6fwLxUqK0

៣. ពេលខ្យល់ព្យុះបក់ខ្លាំង https://youtu.be/lI5A7jKQb2o

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត

**សំភារៈដែលត្រូវការ៖** ប្រើហ្វឺតពណ៌ ដើម្បីសរសេរឈ្មោះពណ៌លើក្រដាសសដោយប្រើពណ៌ខុសៗគ្នា( ឧទាហរណ៍៖សរសេរពាក្យថា "ពណ៌បៃតង" ដោយប្រើហ្វឺត ពណ៌ ក្រហម )

| |
|---|
| បៃតង |
| ក្រហម |
| លឿង |
| ទឹកក្រូច |

១. បែងចែកកុមារជាក្រុម ដោយក្នុងមួយក្រុមត្រូវមានកុមារ៥នាក់

២. ក្រុមនីមួយៗចាត់កុមារម្នាក់មកលេងល្បែងនេះ

៣. បន្ទាប់ពីកុមារតំណាងឲ្យក្រុមនីមួយៗចេញមកហើយ គ្រូត្រូវបង្ហាញក្រដាសដែលមានឈ្មោះពណ៌។ កុមារទី១ដែលបានអានឈ្មោះពណ៌ត្រូវនឹងឈ្នះល្បែងនេះ។ ឧទាហរណ៍៖ បើនៅក្នុងក្រដាសមានពាក្យថា "ពណ៌បៃតង" ប៉ុន្តែពណ៌ដែលសរសេរគឺក្រហម ចំលើយ ដែលត្រឹមត្រូវគឺ "ពណ៌បៃតង"

៤. លេងល្បែងនេះរហូតដល់អស់ពណ៌លេង។

៥. សូមប្រាប់កុមារថាយើងជ្រើសរើសពណ៌ខុស ពីព្រោះយើងមិនគ្រប់លក្ខណ៍ទេ ប៉ុន្តែអ្នកដែលគ្រប់លក្ខណ៍នោះគឺព្រះយេស៊ូវ។

**ជំរើសទី២៖ ( ភ្លើងស្តុប ពណ៌លឿង ក្រហម បៃតង )**

១.ឲ្យកុមារឈរ១ជួរ

២.បើគ្រូស្រែកថាពណ៌លឿងកុមារដើរយឺតៗបើគ្រូស្រែកថាពណ៌បៃតងកុមារត្រូវរត់ទៅមុខឲ្យលឿន ពណ៌ក្រហមកុមារត្រូវឈប់នៅស្ងៀម

៣.បើកុមារណាគាត់មិនឈប់គាត់ត្រូវចាញ់ ឲ្យគាត់នៅមួយកន្លែង យើងបន្តលេងទៀត រហូតនៅសល់កុមារ ៥ ទៅ ១០ នាក់ អាស្រ័យទៅលើការកំណត់របស់គ្រូ។

## ៤. ការណែនាំមេរៀន

តើមនុស្សប្រភេទណាដែលត្រូវប៉ូលីសចាប់ដាក់គុក?គឺជាអ្នកដែលមានទោសពីបទ លួច សំឡាប់ និងអ្នកប្រព្រឹត្តហិង្សាគួរតែជាប់គុក។ តើអ្នកមានអារម្មណ៍យ៉ាងណាបើអ្នកមិនបានធ្វើអ្វីខុស តែត្រូវប៉ូលីសចាប់អ្នកដាក់គុក? តើអ្នកនឹងរកវិធីយ៉ាងណាដើម្បីចេញពីគុកមែនដែរឬទេ? ព្រះយេស៊ូវមិនបានធ្វើអ្វីខុសសោះឡើយនៅក្នុងជីវិតរបស់ទ្រង់។ ទ្រង់ជាព្រះរាជបុត្រានៃព្រះ ប៉ុន្តែព្រះអង្គបានយាងមក ដើម្បីនឹងជួយសង្គ្រោះពួកយើង។ ប៉ុន្តែមនុស្សជាច្រើនបានចាប់ទ្រង់ ហើយចង់សម្លាប់ទ្រង់ថែមទៀតផង។សូមយើងរៀនអំពីរឿងរបស់ព្រះយេស៊ូនៅថ្ងៃនេះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីរបានប្រាប់យើងអំពីគ្រាមួយ ជាពេលដែលព្រះយេស៊ូវជិះសត្វលាទៅកាន់ទីក្រុងយេសាឡិម ហ្វូងមនុស្សបានឈរនៅលើផ្លូវ ហើយគ្រវីមែកចាក។ ពួកគេរំភើបចិត្ត ដោយសារពួកគេខ្លះគិតថាព្រះយេស៊ូវធ្វើដំណើរចូលមកទីក្រុងដើម្បីធ្វើជាស្តេចរបស់ពួកគេ។ ពួកគេស្រែកឡើងថា៖ (**លូកា ១៩៖៣៨**) «ស្ដេចដែលយាងមក ដោយនូវព្រះនាមព្រះអម្ចាស់ ទ្រង់ប្រកបដោយព្រះពរ សូមឲ្យបានសេចក្ដីក្សេមក្សាន្តនៅស្ថានសួគ៌ និងសិរីល្អនៅស្ថានដ៏ខ្ពស់បំផុត» ពួកគេបានចាត់ទុកទ្រង់ដូចជាស្តេចដ៏អស្ចារ្យ។

ប៉ុន្មានថ្ងៃក្រោយ បន្ទាប់ពីចូលទៅក្នុងទីក្រុង ព្រះយេស៊ូត្រូវបានចាប់ខ្លួន នៅពេលដែលទ្រង់មិនបានធ្វើអ្វីខុសសោះ។ អ្នកដឹកនាំមិនបានយល់ថាទ្រង់ជាព្រះរាជបុត្រារបស់ព្រះនោះទេ។ ពួកគេមិនចូលចិត្តស្តាប់មនុស្សសរសើរព្រះយេស៊ូវ ហើយគោរពទ្រង់ដូចជាស្តេចនោះឡើយ។ ដូច្នេះទោះបីជាព្រះយេស៊ូវមិនបានធ្វើអ្វីខុសក៏ដោយ ក៏ពួកគេបានសម្លាប់ទ្រង់ដោយឆ្កាងព្រះយេស៊ូវនៅលើឈើឆ្កាងដែរ។

ប៉ុន្តែព្រះមានផែនការផ្សេងពីនេះ។ ព្រះបានអនុញ្ញាតឲ្យព្រះយេស៊ូវសុគតដើម្បីលោះនូវអំពើបាបរបស់យើងជាកិច្ចការទាំងឡាយណាដែលយើងធ្វើហើយមិនគាប់ព្រះហឫទ័យព្រះ។ ពេលយើងធ្វើអំពើអាក្រក់ យើងសមនឹងទទួលនូវការដាក់ទោស។ អំពើបាបបំបែកយើងចេញពីព្រះ។ ព្រះគម្ពីរ **រ៉ូម៦៖២៣** ចែងថា «ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់ កល្បជានិច្ចដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា»។ ដោយសារព្រះស្រឡាញ់យើង ទើបបានជាទ្រង់បានបញ្ជូនព្រះយេស៊ូវឲ្យមកសុគតជំនួសយើង! ទ្រង់ទទួលទោសជំនួសយើង! ព្រះយេស៊ូមិនគ្រាន់តែសុគតសម្រាប់អ្នកមានឬមនុស្សល្បីនោះទេ។ ព្រះយេស៊ូវបានសុគតសម្រាប់មនុស្សគ្រប់រូប រួមទាំងអ្នកនិងខ្ញុំផង! ដោយសារព្រះយេស៊ូវបានសុគតជំនួសយើងនៅលើឈើឆ្កាង ឥឡូវនេះអ្នកអាចនៅជាមួយនឹងព្រះបាន។ យើងអរព្រះគុណព្រះយេស៊ូវដែលបានសុគតជំនួសយើង។

## ៦. សំនួរពិភាក្សា

១. តើមនុស្សគិតថាព្រះយេស៊ូវនឹងធ្វើអ្វីពេលទ្រង់ចូលក្រុងយេរូសាឡិមដោយជិះសត្វលា?
*(ពួកគេគិតថាទ្រង់នឹងក្លាយជាស្តេច)*
២. តើមានអ្វីកើតឡើងចំពោះព្រះយេស៊ូវ បន្ទាប់ពីពីរបីថ្ងៃក្រោយមក? *(ទ្រង់ត្រូវបានចាប់ខ្លួន ហើយឆ្កាងនៅលើឈើឆ្កាង)*
៣. តើអំពើបាបធ្វើអ្វីចំពោះទំនាក់ទំនងរបស់យើងជាមួយព្រះ? *(វាបំបែកយើងពីព្រះ)*
៤. ដោយសារព្រះយេស៊ូវបានសុគតជំនួសយើង តើមានអ្វីកើតឡើងចំពោះអំពើបាបរបស់យើង?
*(ព្រះយេស៊ូវបានទទួលយកអំពើបាបរបស់យើង ហើយសុគតជំនួសអំពើបាបរបស់យើង។*

៥. តើអ្នកអាចអរព្រះគុណព្រះយេស៊ូដែលបានសុគតជំនួសអ្នកយ៉ាងដូចម្ដេច ដើម្បីឲ្យអ្នកបាននៅជាមួយនឹងព្រះ? *(អនុញ្ញាតឱ្យកុមារឆ្លើយ - អធិស្ឋាន អានព្រះគម្ពីរ សប្បុរស ស្រឡាញ់អ្នកដទៃទៀត; ឲ្យកុមារនិយាយថា អរគុណព្រះយេស៊ូវដែលបានសុគត់ជំនួសអំពើបាបយើង)*

### ៧. ល្បែងកំសាន្ត

សម្ភារៈដែលត្រូវការៈ ក្រដាស៤០-៥០ សន្លឹក



១.សុំឱ្យកុមារឆ្នូលក្រដាសឱ្យបានច្រើនសន្លឹកតាម ដែលអាចធ្វើទៅបាន ហើយដាក់វានៅកណ្ដាលបន្ទប់។

២. ចែកកុមារជា ២ ក្រុម។

៣. ក្រដាសដែលបានឆ្នូលទាំងនោះតំណាងឱ្យអំពើបាបនៅក្នុងជីវិតរបស់យើង។

៤.ក្រុមទី ១ នឹងព្យាយាមគប់អំពើបាបរបស់ពួកគេសំដៅទៅកាន់ក្រុមទី ២ ។

នេះតំណាងឱ្យពួកគ្រីស្ទានដែលព្យាយាមរស់នៅក្នុងជីវិតរស់នៅដូចជាព្រះ។

៥. ក្រុមទី២ នឹងគប់ក្រដាសត្រឡប់ទៅក្រុមទី ១។

នេះតំណាងឱ្យលោកិយដែលធ្វើឱ្យយើងមានការលំបាកក្នុងការរួចផុតពីអំពើបាប។

៦. ក្រុមទី ១ ត្រូវតែប្រឹងប្រែងដើម្បីបោះចោលក្រដាសឆ្នូលឲ្យបានច្រើនចេញឆ្ងាយពីពួកគេដើម្បីឈ្នះការប្រកួត (គ្រូត្រូវកំណត់នាទីក្នុងការលេងល្បែងនេះ)

៧. ពន្យល់ដល់កុមារថា វាមិនអាចទៅរួចទេសម្រាប់យើងដើម្បីកម្ចាត់អំពើបាបរបស់យើងទាំងអស់ ចេញបាន។ ដូច្នេះហើយបានជាព្រះយេស៊ូវបានសុគតជំនួសយើងនៅលើឈើឆ្កាង។ ព្រះយេស៊ូវបានទទួលយកអំពើបាបរបស់យើងទាំងអស់ ។ ឥឡូវនេះ យើងត្រូវតែជ្រើសរើសរស់នៅជាមួយនឹងជីវិត ដែលធ្វើឲ្យព្រះសព្វព្រះទ័យ។

### ៨. ខគម្ពីរចងចាំ

**រ៉ូម ៦:២៣** «ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា»។

### ៩. ហត្ថកម្ម

សូមឲ្យកុមារផាត់ពណ៌លើរូបឈើឆ្កាង ហើយឲ្យពួកគេចាំថាព្រះយេស៊ូវបានសុគតជំនួសបាបយើង។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ដោយសារតែជីវិតរបស់យើងគឺមានភាពរវល់ខ្លាំងណាស់ ដែលវាងាយស្រួលធ្វើឲ្យយើងភ្លេចថាព្រះ គឺជាអ្វីគ្រប់យ៉ាងនៅក្នុងជីវិតនេះ។ ប៉ុន្តែអ្វីៗគ្រប់យ៉ាងដែលបានបង្កើតឡើងមកនោះ ប្រាប់យើងថា ទ្រង់ជាព្រះអទិករ។ សូមអរព្រះគុណព្រះ ដែលយើងមានក្ដីស្រឡាញ់ និងមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូវ! ដូចជានៅក្នុងព្រះគម្ពីរបាន បង្រៀនយើងនៅថ្ងៃនេះ សូម្បីតែថ្មក៏អាចសរសើរដំកើងព្រះយេស៊ូវបានដែរ។ រើសថ្ម តើពាក្យនេះប្រាប់យើងអ្វីខ្លះពីព្រះ? វាគួរតែប្រាប់អ្នកពីការអស្ចារ្យ របស់ព្រះអាទិករដែលគ្មានការចាប់ផ្ដើមហើយក៏មានទីបញ្ចប់។ សូម សរសេរដំកើងព្រះមេស្ស៊ីរបស់អ្នក គ្រប់ពេលទាំងអស់។

បៃតង

ក្រហម

លឿង

ទឹកក្រូច

# ព្រះយេស៊ូវនៅលើឈើឆ្កាង

